## ព្រះរាជាណាចក្រកម្ពុជា
## ជាតិ សាសនា ព្រះមហាក្សត្រ

# កិច្ចព្រមព្រៀងសម្រាប់អនុវត្តបទប្បញ្ញត្តិនៃអនុសញ្ញាសហប្រជាជាតិ ស្តីពីច្បាប់សមុទ្រចុះថ្ងៃទី១០ ខែធ្នូ ឆ្នាំ១៩៨២ ទាក់ទងនឹងការគ្រប់គ្រង និង ការអភិរក្សផលស្តុកត្រីផ្លាស់ទីមធ្យមនិងផលស្តុកត្រីផ្លាស់ទីឆ្ងាយ



ខែមីនា ឆ្នាំ២០២០

# មាតិកា


បុព្វកថា ........................................................................ 1
ផ្នែកទី១. បទប្បញ្ញត្តិទូទៅ ........................................................................ 2
មាត្រា១. ការប្រើវាក្យសព្ទនិងវិសាលភាព ........................................................................ 2
មាត្រា២. គោលដៅ ........................................................................ 2
មាត្រា៣. ការអនុវត្ត ........................................................................ 2
មាត្រា៤. ទំនាក់ទំនងរវាងកិច្ចព្រមព្រៀងនេះនិងអនុសញ្ញា ........................................................................ 3
ផ្នែកទី២. ការគ្រប់គ្រងនិងការអភិរក្សផលស្តុកត្រីផ្លាស់ទីមធ្យមនិងផលស្តុកត្រីផ្លាស់ទីឆ្ងាយ ........................................................................ 3
មាត្រា៥. គោលការណ៍ទូទៅ ........................................................................ 3
មាត្រា៦. ការអនុវត្តអភិក្រមប្រុងប្រយ័ត្នជាមុន ........................................................................ 4
មាត្រា៧. ភាពស្របគ្នានៃវិធានការគ្រប់គ្រងនិងអភិរក្ស ........................................................................ 5
ផ្នែកទី៣.យន្តការសម្រាប់កិច្ចសហប្រតិបត្តិការអន្តរជាតិពាក់ព័ន្ធនឹងផលស្តុកត្រីផ្លាស់ទីមធ្យមនិងផលស្តុកត្រីផ្លាស់ទីឆ្ងាយ ........................................................................ 7
មាត្រា៨. កិច្ចសហប្រតិបត្តិការសម្រាប់ការគ្រប់គ្រងនិងការអភិរក្ស ........................................................................ 7
មាត្រា៩. អង្គការនិងក្រុមការងារគ្រប់គ្រងជលផលថ្នាក់តំបន់និងអនុតំបន់ ........................................................................ 8
មាត្រា១០. ការប្រព្រឹត្តទៅរបស់អង្គការឬក្រុមការងារគ្រប់គ្រងជលផលថ្នាក់តំបន់និងអនុតំបន់ ........................................................................ 9
មាត្រា១១. សមាជិកឬអ្នកចូលរួមថ្មី ........................................................................ 10
មាត្រា១២.តម្លាភាពនៅក្នុងសកម្មភាពរបស់អង្គការនិងក្រុមការងារគ្រប់គ្រងជលផលថ្នាក់តំបន់និងអនុតំបន់ ........................................................................ 10
មាត្រា១៣. ការពង្រឹងអង្គការនិងក្រុមការងារដែលមានស្រាប់ ........................................................................ 10
មាត្រា១៤.ការប្រមូលនិងផ្តល់ព័ត៌មាននិងកិច្ចសហប្រតិបត្តិការក្នុងការសិក្សាស្រាវជ្រាវវិទ្យាសាស្ត្រ ........................................................................ 11
មាត្រា១៥. សមុទ្រក្នុងនិងឈូងសមុទ្រ ........................................................................ 11
មាត្រា១៦.តំបន់សមុទ្រអន្តរជាតិព័ទ្ធជុំវិញទាំងស្រុងដោយតំបន់សមុទ្រស្ថិតនៅក្រោមដែនយុត្តាធិការនៃរដ្ឋទោលមួយ ........................................................................ 11
ផ្នែកទី៤.រដ្ឋមិនមែនជាសមាជិកនិងរដ្ឋមិនមែនជាអ្នកចូលរួម ........................................................................ 12
មាត្រា១៧.រដ្ឋមិនមែនជាសមាជិករបស់អង្គការនិងរដ្ឋមិនមែនជាអ្នកចូលរួមនៅក្នុងក្រុមការងារ ........................................................................ 12
ផ្នែកទី៥. កាតព្វកិច្ចរបស់រដ្ឋម្ចាស់ទង់ជាតិ ........................................................................ 13
មាត្រា១៨. កាតព្វកិច្ចរបស់រដ្ឋម្ចាស់ទង់ជាតិ ........................................................................ 13
ផ្នែកទី៦. ការគោរពនិងការអនុវត្តច្បាប់ ........................................................................ 14
មាត្រា១៩. ការគោរពនិងការអនុវត្តច្បាប់ដោយរដ្ឋម្ចាស់ទង់ជាតិ ........................................................................ 14
មាត្រា២០. កិច្ចសហប្រតិបត្តិការអន្តរជាតិក្នុងការអនុវត្តច្បាប់ ........................................................................ 15
មាត្រា២១. កិច្ចសហប្រតិបត្តិការថ្នាក់តំបន់និងអនុតំបន់ក្នុងការអនុវត្តច្បាប់ ........................................................................ 16
មាត្រា២២. នីតិវិធីជាមូលដ្ឋានសម្រាប់ការឡើងនិងការធ្វើអធិការកិច្ចលើនាវាស្របតាម ........................................................................ 19
មាត្រា២៣. វិធានការដែលត្រូវប្រកាន់យកដោយរដ្ឋម្ចាស់កំពង់ផែ ........................................................................ 20
ផ្នែកទី៧. តម្រូវការរបស់រដ្ឋកំពុងអភិវឌ្ឍ ........................................................................ 21

មាត្រា២៤. ការទទួលស្គាល់តម្រូវការពិសេសរបស់រដ្ឋកំពុងអភិវឌ្ឍ 21
មាត្រា២៥. ទម្រង់នៃកិច្ចសហការជាមួយរដ្ឋកំពុងអភិវឌ្ឍ 21
មាត្រា២៦. ជំនួយពិសេសក្នុងការអនុវត្តកិច្ចព្រមព្រៀងនេះ 22
ផ្នែកទី៨. ការដោះស្រាយវិវាទដោយសន្តិវិធី 22
មាត្រា២៧. កាតព្វកិច្ចដើម្បីដោះស្រាយវិវាទដោយសន្តិវិធី 22
មាត្រា២៨. ការបង្ការវិវាទ 22
មាត្រា២៩. វិវាទផ្នែកបច្ចេកទេស 22
មាត្រា៣០. នីតិវិធីដោះស្រាយវិវាទ 22
មាត្រា៣១. វិធានការបណ្តោះអាសន្ន 23
មាត្រា៣២. ដែនកំណត់ស្តីពីនីតិវិធីដែលអាចអនុវត្តបានក្នុងការដោះស្រាយវិវាទ 24
ផ្នែកទី៩. ភាគីមិនមែនជាសមាជិកក្នុងកិច្ចព្រមព្រៀង 24
មាត្រា៣៣. ភាគីមិនមែនជាសមាជិកក្នុងកិច្ចព្រមព្រៀង 24
ផ្នែកទី១០. ការជឿទុកចិត្តនិងការរំលោភសិទ្ធិ 24
មាត្រា៣៤. ការជឿទុកចិត្តនិងការរំលោភសិទ្ធិ 24
ផ្នែកទី១១. ភារកិច្ចនិងភាពទទួលខុសត្រូវ 24
មាត្រា៣៥. ភារកិច្ចនិងភាពទទួលខុសត្រូវ 24
ផ្នែកទី១២. សន្និសីទពិនិត្យឡើងវិញ 24
មាត្រា៣៦. សន្និសីទពិនិត្យឡើងវិញ 24
ផ្នែកទី១៣. អវសានប្បញ្ញត្តិ 25
មាត្រា៣៧. ការចុះហត្ថលេខា 25
មាត្រា៣៨. ការផ្តល់សច្ចាប័ន 25
មាត្រា៣៩. ការចូលជាសមាជិក 25
មាត្រា៤០. ការចូលជាធរមាន 25
មាត្រា៤១. ការអនុវត្តបណ្តោះអាសន្ន 25
មាត្រា៤២. ការបម្រុងទុកនិងការលើកលែង 26
មាត្រា៤៣. សេចក្តីប្រកាសនិងសេចក្តីថ្លែងការណ៍ 26
មាត្រា៤៤. ទំនាក់ទំនងជាមួយកិច្ចព្រមព្រៀងផ្សេងទៀត 26
មាត្រា៤៥. វិសោធនកម្ម 26
មាត្រា៤៦. ការប្តឹងជំទាស់ 27
មាត្រា៤៧.ការចូលរួមដោយអង្គការអន្តរជាតិ 27
មាត្រា៤៨. ឧបសម្ព័ន្ធ 28
មាត្រា៤៩.អ្នកតម្កល់ឯកសារ 28
មាត្រា៥០.យថាភូតភាពនៃកិច្ចព្រមព្រៀង 28
ឧបសម្ព័ន្ធទី១.តម្រូវការស្តង់ដារសម្រាប់ការប្រមូលនិងការចែករំលែកទិន្នន័យ 30
មាត្រា១. គោលការណ៍ទូទៅ 30

មាត្រា២. គោលការណ៍នៃការប្រមូល ការចងក្រង និងការផ្លាស់ប្តូរទិន្នន័យ ........ 30
មាត្រា៣. ទិន្នន័យផលផលជាមូលដ្ឋាន ........ 31
មាត្រា៤. ទិន្នន័យនិងព័ត៌មាននាវានេសាទ ........ 31
មាត្រា៥. ការរាយការណ៍ ........ 31
មាត្រា៦. ការផ្ទៀងផ្ទាត់ទិន្នន័យ ........ 32
មាត្រា៧. ការផ្លាស់ប្តូរទិន្នន័យ ........ 32
ឧបសម្ព័ន្ធទី២.គោលការណ៍ណែនាំសម្រាប់អនុវត្តអភិក្រមប្រុងប្រយ័ត្នជាមុន ក្នុងការគ្រប់គ្រង និងអភិរក្សផលស្តុកត្រីផ្លាស់ទីមធ្យមឬផលស្តុកត្រីផ្លាស់ទីឆ្ងាយ ........ 34
ឧបសម្ព័ន្ធទី៣.ព្រះរាជក្រមប្រកាសឱ្យប្រើច្បាប់ស្តីពីការអនុម័តយល់ព្រមឱ្យព្រះរាជាណាចក្រកម្ពុជាចូលជាសមាជិកនៃកិច្ចព្រមព្រៀងសម្រាប់អនុវត្តបទប្បញ្ញត្តិនៃអនុសញ្ញាសហប្រជាជាតិស្តីពីច្បាប់សមុទ្រចុះថ្ងៃទី១០ ខែធ្នូ ឆ្នាំ១៩៨២ ទាក់ទងនឹងការគ្រប់គ្រងនិងការអភិរក្សផលស្តុកត្រីផ្លាស់ទីមធ្យមនិងផលស្តុកត្រីផ្លាស់ទីឆ្ងាយ ........ 34

## បុព្វកថា

# រដ្ឋភាគីនៅក្នុងកិច្ចព្រមព្រៀងនេះ

**ដោយរំលឹកឡើងវិញ**នូវបទប្បញ្ញត្តិពាក់ព័ន្ធនានានៃអនុសញ្ញាសហប្រជាជាតិស្ដីពីច្បាប់សមុទ្រ ចុះថ្ងៃទី១០ ខែធ្នូ ឆ្នាំ ១៩៨២។

**ដោយកំណត់ក្នុងការធានា**ដល់ការអភិរក្សយូរអង្វែងនិងការប្រើប្រាស់ប្រកបដោយនិរន្តរភាពនៃផលស្តុកត្រីផ្លាស់ទីមធ្យមនិងផលស្តុកត្រីផ្លាស់ទីឆ្ងាយ។

**ដោយមានការសម្រេចចិត្ត** ដើម្បីធ្វើឱ្យប្រសើរឡើងនូវកិច្ចសហប្រតិបត្តិការរវាងរដ្ឋនានាក្នុងគោលដៅរួម។

**ដោយអំពាវនាវ**ឱ្យមានការអនុវត្តច្បាប់ប្រកបដោយប្រសិទ្ធភាពរបស់រដ្ឋម្ចាស់ទង់ជាតិ រដ្ឋម្ចាស់កំពង់ផែ និងរដ្ឋម្ចាស់ឆ្នេរលើវិធានការគ្រប់គ្រងនិងអភិរក្សដែលបានអនុម័តសម្រាប់ផលស្តុកទាំងនោះ។

**ដោយស្វែងរកដំណោះស្រាយ**ក្នុងការឆ្លើយតបនឹងបញ្ហា ជាពិសេស បញ្ហាដែលបានកំណត់នៅក្នុងជំពូក១៧ កម្មវិធី "គ" នៃរបៀបវារៈ២១ដែលបានអនុម័តដោយសន្និសីទសហប្រជាជាតិស្ដីពីបរិស្ថាននិងការអភិវឌ្ឍ ដូចជាការគ្រប់គ្រងជលផលនៅក្នុងដែនសមុទ្រអន្តរជាតិនៅមានភាពខ្វះចន្លោះនៅក្នុងតំបន់ជាច្រើន ហើយធនធានមួយចំនួនត្រូវបានប្រើប្រាស់ហួសកម្រិត។ ដោយកត់សម្គាល់ឃើញថាមានបញ្ហាជាច្រើនដូចជា ការនេសាទដោយគ្មានការអនុញ្ញាត ការប្រើប្រាស់មូលធនហួសកម្រិត ចំនួននាវានេសាទច្រើនហួសកម្រិត នាវាដែលប្ដូរទង់ជាតិដើម្បីគេចចេញពីការត្រួតពិនិត្យ ឧបករណ៍នេសាទជ្រើសរើសគោលដៅមិនទាន់បានរៀបចំល្អ ទិន្នន័យមូលដ្ឋានដែលមិនអាចជឿជាក់បាន និងកង្វះកិច្ចសហប្រតិបត្តិការរវាងរដ្ឋនិងរដ្ឋ។

**ដោយប្តេជ្ញាចិត្ត**ពីរដ្ឋសាមីទាំងអស់ក្នុងការធ្វើនេសាទប្រកបដោយការទទួលខុសត្រូវ។

**ដោយមនសិការយល់ឃើញ**ពីតម្រូវការនៃការបញ្ចៀសផលប៉ះពាល់ប្រកបដោយគ្រោះថ្នាក់ ទៅលើបរិស្ថានសមុទ្រ ការរក្សាជីវៈចម្រុះ ការថែរក្សាប្រព័ន្ធអេកូឡូស៊ីសមុទ្រ និងការកាត់បន្ថយជាអប្បបរមានូវហានិភ័យនៃផលប៉ះពាល់យូរអង្វែងឬមិនអាចស្តារផលប៉ះពាល់នៃការធ្វើនេសាទ។

**ដោយទទួលស្គាល់**នូវតម្រូវការសម្រាប់ជំនួយជាក់លាក់រាប់បញ្ចូលទាំងជំនួយផ្នែកហិរញ្ញវត្ថុ វិទ្យាសាស្ត្រ និងបច្ចេកវិទ្យាដល់រដ្ឋកំពុងអភិវឌ្ឍអាចចូលរួមគ្រប់គ្រង អភិរក្ស និងប្រើប្រាស់ផលស្តុកត្រីផ្លាស់ទីមធ្យម និងផលស្តុកត្រីផ្លាស់ទីឆ្ងាយប្រកបដោយប្រសិទ្ធភាពនិងនិរន្តរភាព។

**ដោយមានការជឿជាក់**ថាកិច្ចព្រមព្រៀងសម្រាប់អនុវត្តបទប្បញ្ញត្តិពាក់ព័ន្ធនៃអនុសញ្ញា នឹងបម្រើដល់គោលបំណងទាំងអស់ឱ្យល្អប្រសើរ និងចូលរួមចំណែកដល់ការថែរក្សាសន្តិភាពនិងសន្តិសុខអន្តរជាតិ។

**ដោយអះអាងថា**បញ្ហានានាដែលមិនបានកំណត់ក្នុងអនុសញ្ញាឬកិច្ចព្រមព្រៀងនេះ នឹងបន្តគ្រប់គ្រងដោយច្បាប់ និងគោលការណ៍ច្បាប់អន្តរជាតិទូទៅ។

បានព្រមព្រៀងគ្នាដូចតទៅ៖

## ផ្នែកទី១. បទប្បញ្ញត្តិទូទៅ

### មាត្រា១. ការប្រើវាក្យសព្ទនិងវិសាលភាព

១. សម្រាប់គោលបំណងនៃកិច្ចព្រមព្រៀងនេះ វាក្យសព្ទខាងក្រោមមានន័យដូចតទៅ៖

(ក) "**អនុសញ្ញា**" មានន័យថាអនុសញ្ញាសហប្រជាជាតិស្តីពីច្បាប់សមុទ្រ ចុះថ្ងៃទី១០ ខែធ្នូ ឆ្នាំ១៩៨២

(ខ) "**វិធានការគ្រប់គ្រងនិងអភិរក្ស**" មានន័យថា វិធានការទាំងឡាយសម្រាប់គ្រប់គ្រង និងអភិរក្សប្រភេទធនធានសមុទ្រមានជីវិតមួយឬច្រើន ដែលត្រូវបានអនុម័តនិងអនុវត្តដោយមានសង្គតិភាពជាមួយនឹងវិធាននៃច្បាប់អន្តរជាតិពាក់ព័ន្ធ ដូចមានចែងក្នុងអនុសញ្ញានិងកិច្ចព្រមព្រៀងនេះ

(គ) "**ត្រី**" រាប់បញ្ចូលទាំងសិប្បីសត្វនិងពពួកក្តាម លើកលែងតែពពួកដែលស្ថិតក្នុងប្រភេទដែលមិនធ្វើបម្លាស់ទី ដូចបានកំណត់ក្នុងមាត្រា៧៧នៃអនុសញ្ញា

(ឃ) "**ការរៀបចំ**" មានន័យថា យន្តការសហប្រតិបត្តិការមួយដែលបានបង្កើតឡើងស្របតាមអនុសញ្ញានិងកិច្ចព្រមព្រៀងនេះដោយរដ្ឋពីរឬច្រើន ក្នុងគោលបំណងដូចជាការបង្កើតវិធានការគ្រប់គ្រងនិងអភិរក្សនានាក្នុងតំបន់ឬអនុតំបន់មួយ ដែលប្រើសម្រាប់ផលស្តុកត្រីផ្លាស់ទីមធ្យមនិងផលស្តុកត្រីផ្លាស់ទីឆ្ងាយតែមួយប្រភេទឬច្រើនប្រភេទ

២. (ក) "**រដ្ឋភាគី**" មានន័យថា រដ្ឋទាំងឡាយណាដែលបានយល់ព្រមនិងមានកាតព្វកិច្ចអនុវត្តកិច្ចព្រមព្រៀងនេះ ហើយកិច្ចព្រមព្រៀងនេះត្រូវស្ថិតជាធរមានសម្រាប់រដ្ឋនោះ

(ខ) ក្នុងករណីចាំបាច់ បើមានការកែសម្រួលមិនឱ្យប៉ះពាល់ដល់អត្ថន័យដើម កិច្ចព្រមព្រៀងនេះត្រូវអនុវត្តចំពោះ៖

(i) អង្គភាពណាមួយដែលមានចែងក្នុងមាត្រា៣០៥ កថាខណ្ឌទី១ (គ) (ឃ) និង (ង) នៃអនុសញ្ញា

(ii) ផ្អែកលើមាត្រា៤៧ សំដៅដល់អង្គភាពណាមួយដែលជាអង្គការអន្តរជាតិមួយដែលមានចែងក្នុងឧបសម្ព័ន្ធ៩ មាត្រា១នៃអនុសញ្ញា ដែលបានក្លាយជាភាគីនៃកិច្ចព្រមព្រៀងនេះ និង"រដ្ឋភាគី" សំដៅដល់អង្គភាពទាំងនោះ។

៣. កិច្ចព្រមព្រៀងនេះអនុវត្តដោយមានការកែសម្រួល មិនឱ្យប៉ះពាល់ដល់អត្ថន័យដើម ក្នុងករណីចាំបាច់ចំពោះអង្គភាពនេសាទដទៃទៀតដែលនាវារបស់ពួកគេធ្វើនេសាទនៅសមុទ្រអន្តរជាតិ។

### មាត្រា២. គោលដៅ

គោលដៅនៃកិច្ចព្រមព្រៀងនេះ គឺធានាដល់ការអភិរក្សយូរអង្វែងនិងការប្រើប្រាស់ប្រកបដោយនិរន្តរភាពនូវផលស្តុកត្រីផ្លាស់ទីមធ្យម និងផលស្តុកត្រីផ្លាស់ទីឆ្ងាយ តាមរយៈការអនុវត្តប្រកបដោយប្រសិទ្ធភាពនូវបទប្បញ្ញត្តិពាក់ព័ន្ធនានានៃអនុសញ្ញា។

### មាត្រា៣. ការអនុវត្ត

១. លើកលែងតែមានការចែងផ្ទុយពីនេះ កិច្ចព្រមព្រៀងនេះអនុវត្តសម្រាប់ការគ្រប់គ្រងនិងការអភិរក្សផលស្តុកត្រីផ្លាស់ទីមធ្យមនិងផលស្តុកត្រីផ្លាស់ទីឆ្ងាយនៅក្នុងតំបន់ហួសពីដែនយុត្តាធិការជាតិ លើកលែងតែមាត្រា៦និងមាត្រា៧ ដែលអនុវត្តចំពោះការគ្រប់គ្រងនិងការអភិរក្សផលស្តុកត្រីខាងលើនៅក្រោមតំបន់ស្ថិតក្នុងដែនយុត្តា

ធិការជាតិអាស្រ័យនឹងច្បាប់ផ្សេងៗគ្នាដែលអនុវត្តនៅក្នុងតំបន់ក្រោមដែនយុត្តាធិការជាតិ និងនៅក្នុងតំបន់ក្រៅពីដែនយុត្តាធិការជាតិ ដូចមានចែងនៅក្នុងអនុសញ្ញា។

២. ក្នុងការអនុវត្តសិទ្ធិអធិបតេយ្យភាពជាតិក្នុងគោលបំណងរុករកនិងធ្វើអាជីវកម្ម គ្រប់គ្រងនិងអភិរក្ស ផលស្តុកត្រីផ្លាស់ទីមធ្យមនិងផលស្តុកត្រីផ្លាស់ទីឆ្ងាយនៅក្នុងតំបន់ស្ថិតក្រោមដែនយុត្តាធិការជាតិ រដ្ឋម្ចាស់ឆ្នេរនឹងអនុវត្តគោលការណ៍ទូទៅ ដោយមានការកែសម្រួលមិនឱ្យប៉ះពាល់ដល់អត្ថន័យដើមក្នុងករណីចាំបាច់ដូចមានចែងក្នុងមាត្រា៥។

៣. រដ្ឋនានាត្រូវពិចារណាឱ្យបានត្រឹមត្រូវលើសមត្ថភាពនៃរដ្ឋកំពុងអភិវឌ្ឍ ដើម្បីអនុវត្តមាត្រា៥ មាត្រា៦ និងមាត្រា៧នៅក្នុងតំបន់ស្ថិតក្រោមដែនយុត្តាធិការជាតិ និងលើសេចក្តីត្រូវការជំនួយរបស់រដ្ឋទាំងនោះ ដូចមានចែងនៅក្នុងកិច្ចព្រមព្រៀងនេះ។ដើម្បីសម្រេចបាននូវទិសដៅនេះផ្នែក៧ នឹងអនុវត្តដោយមានការកែសម្រួលមិនឱ្យប៉ះពាល់ដល់អត្ថន័យដើម ក្នុងករណីចាំបាច់ ចំពោះតំបន់ស្ថិតនៅក្រោមដែនយុត្តាធិការជាតិ។

## មាត្រា៤. ទំនាក់ទំនងរវាងកិច្ចព្រមព្រៀងនេះនិងអនុសញ្ញា

គ្មានបទប្បញ្ញត្តិណាមួយនៅក្នុងកិច្ចព្រមព្រៀងនេះដែលបង្កព្យសនកម្មចំពោះសិទ្ធិ យុត្តាធិការ និងករណីយកិច្ចរបស់រដ្ឋនៅក្នុងអនុសញ្ញា។ កិច្ចព្រមព្រៀងនេះនឹងត្រូវបកស្រាយនិងអនុវត្តក្នុងបរិបទ ដោយមានសង្គតិភាពជាមួយអនុសញ្ញា។

# ផ្នែកទី២. ការគ្រប់គ្រងនិងការអភិរក្សផលស្តុកត្រីផ្លាស់ទីមធ្យមនិងផលស្តុកត្រីផ្លាស់ទីឆ្ងាយ

## មាត្រា៥. គោលការណ៍ទូទៅ

ដើម្បីគ្រប់គ្រងនិងអភិរក្សផលស្តុកត្រីផ្លាស់ទីមធ្យមនិងផលស្តុកត្រីផ្លាស់ទីឆ្ងាយ និងបង្កើនប្រសិទ្ធភាពការងារក្នុងកិច្ចសហប្រតិបត្តិការឱ្យស្របតាមអនុសញ្ញា រដ្ឋម្ចាស់ឆ្នេរនិងរដ្ឋដែលធ្វើនេសាទនៅដែនសមុទ្រអន្តរជាតិត្រូវ៖

(ក) អនុម័តវិធានការដើម្បីធានានិរន្តរភាពយូរអង្វែងនៃផលស្តុកត្រីផ្លាស់ទីមធ្យម និងផលស្តុកត្រីផ្លាស់ទីឆ្ងាយ និងលើកកម្ពស់គោលបំណងនៃការប្រើប្រាស់ផលស្តុកត្រីទាំងនោះឱ្យបានល្អបំផុត

(ខ) ធានាថាវិធានការទាំងនោះ គឺផ្អែកទៅលើភស្តុតាងវិទ្យាសាស្ត្រប្រសើរបំផុតដែលមាននិងត្រូវបានរៀបចំឡើងសម្រាប់ថែរក្សាឬស្តារផលស្តុកត្រីទាំងនោះឡើងវិញ នៅកម្រិតដែលអាចផលិតបាននូវទិន្នផលនិរន្តរភាពអតិបរមា ដែលសមស្របតាមកត្តាសេដ្ឋកិច្ចនិងបរិស្ថានពាក់ព័ន្ធដោយរាប់បញ្ចូលទាំងតម្រូវការពិសេសរបស់រដ្ឋកំពុងអភិវឌ្ឍនិងគិតទៅដល់បែបផែននៃការធ្វើនេសាទការពឹងអាស្រ័យគ្នាទៅវិញទៅមកនៃផលស្តុកត្រី និងស្តង់ដារអន្តរជាតិអប្បបរមាដែលបានណែនាំជាទូទៅសម្រាប់ថ្នាក់អនុតំបន់ តំបន់ ឬសកល

(គ) អនុវត្តអភិក្រមប្រុងប្រយ័ត្នជាមុន ស្របតាមមាត្រា៦

(ឃ) វាយតម្លៃផលប៉ះពាល់ពីការធ្វើនេសាទ សកម្មភាពផ្សេងៗរបស់មនុស្ស និងកត្តាបរិស្ថានទៅលើផលស្តុកគោលដៅនិងប្រភេទត្រី ស្ថិតក្នុងប្រព័ន្ធអេកូឡូស៊ីតែមួយឬមានទំនាក់ទំនងជាមួយគ្នាឬពឹងអាស្រ័យលើផលស្តុកគោលដៅ

(ង) ក្នុងករណីចាំបាច់ អនុម័តវិធានការគ្រប់គ្រងនិងអភិរក្សសម្រាប់ប្រភេទដែលស្ថិតនៅក្នុងប្រព័ន្ធអេកូឡូស៊ីដូចគ្នា ឬមានទំនាក់ទំនងជាមួយគ្នា ឬពឹងអាស្រ័យលើផលស្តុកគោលដៅ ដោយឈរលើ ទស្សនៈថែ

រក្សានិងស្តារឡើងវិញនូវបរិមាណនៃប្រភេទត្រីទាំងនោះ ឱ្យមានកម្រិតខ្ពស់លើសពីកម្រិតនៃការបន្តពូជរបស់ពួកវាដែលអាចស្ថិតក្នុងការគំរាមកំហែងយ៉ាងធ្ងន់ធ្ងរ

(ច) កាត់បន្ថយឱ្យដល់កម្រិតអប្បបរមានូវការបំពុល កាកសំណល់ ការបោះចោល ការជាប់ត្រីដោយឧបករណ៍នេសាទបោះបង់ចោល ផលនេសាទដែលមិនមែនជាប្រភេទគោលដៅនៃការធ្វើនេសាទ ទាំងជាប្រភេទត្រី ទាំងពពួកមិនមែនជាប្រភេទត្រី (កំណត់ថាមិនមែនជាប្រភេទគោលដៅ) និងផលប៉ះពាល់លើប្រភេទត្រីពាក់ព័ន្ធឬប្រភេទត្រីដែលពឹងអាស្រ័យ ជាពិសេស ប្រភេទត្រីដែលកំពុងរងគ្រោះ តាមរយៈវិធានការទាំងឡាយ តាមលទ្ធភាពដែលអាចអនុវត្តបាន ដូចជាការបង្កើតនិងការប្រើប្រាស់ឧបករណ៍ និងបច្ចេកទេសនេសាទចាប់ប្រភេទត្រីគោលដៅ ដោយមិនប៉ះពាល់ដល់បរិស្ថាននិងមានប្រសិទ្ធភាពស្របនឹងតម្លៃ

(ឆ) ការពារជីវៈចម្រុះនៅក្នុងបរិស្ថានសមុទ្រ

(ជ) ចាត់វិធានការដើម្បីការពារឬលុបបំបាត់ការនេសាទហួសកម្រិត និងសមត្ថភាពនេសាទហួសកម្រិត ដើម្បីធានាថាកម្រិតនៃការនេសាទមិនលើសពីកម្រិតដែលសមាមាត្រ នឹងការប្រើប្រាស់ធនធានជលផលប្រកបដោយនិរន្តរភាព

(ឈ) យកចិត្តទុកដាក់ទៅលើផលប្រយោជន៍របស់អ្នកនេសាទជាលក្ខណៈប្រពៃណី និងអ្នកនេសាទគ្រួសារ

(ញ) ប្រមូលនិងចែករំលែកឱ្យទាន់ពេលវេលានូវទិន្នន័យ ដែលទាក់ទងទៅនឹងសកម្មភាពនេសាទឱ្យបានច្បាស់លាស់និងគ្រប់ជ្រុងជ្រោយ មានជាអាទិ៍ ទីតាំងនាវា ផលនេសាទនៃប្រភេទត្រីគោលដៅនិងមិនមែនគោលដៅ និងសមត្ថភាពនេសាទ ដូចមានចែងក្នុងឧបសម្ព័ន្ធ១ ក៏ដូចជាព័ត៌មានដែលបានពីកម្មវិធីស្រាវជ្រាវជាតិនិងអន្តរជាតិ

(ដ) លើកកម្ពស់និងស្រាវជ្រាវផ្នែកវិទ្យាសាស្ត្រ ព្រមទាំងអភិវឌ្ឍបច្ចេកវិទ្យាសមស្របក្នុងការគាំទ្រដល់ការគ្រប់គ្រងនិងការអភិរក្សជលផល

(ឋ) អនុវត្តនិងពង្រឹងវិធានការគ្រប់គ្រងនិងអភិរក្សតាមរយៈការតាមដាន ត្រួតពិនិត្យ និងអង្កេតប្រកបដោយប្រសិទ្ធភាព។

## មាត្រា៦. ការអនុវត្តអភិក្រមប្រុងប្រយ័ត្នជាមុន

១. រដ្ឋនានាត្រូវអនុវត្តអភិក្រមប្រុងប្រយ័ត្នជាមុនឱ្យបានទូលំទូលាយដើម្បីគ្រប់គ្រង អភិរក្ស និងធ្វើអាជីវកម្មផលស្តុកត្រីផ្លាស់ទីមធ្យមនិងផលស្តុកត្រីផ្លាស់ទីឆ្ងាយ ដើម្បីការពារធនធានសមុទ្រមានជីវិតនិងថែរក្សាបរិស្ថានសមុទ្រ។

២. រដ្ឋនានាត្រូវប្រុងប្រយ័ត្នខ្ពស់នៅពេលដែលមានព័ត៌មានមិនជាក់លាក់ មិនអាចជឿជាក់បាន ឬមិនគ្រប់គ្រាន់។ អវត្តមាននៃព័ត៌មានវិទ្យាសាស្ត្រគ្រប់គ្រាន់មិនត្រូវបានប្រើជាមូលហេតុសម្រាប់ការពន្យារឬការបដិសេធលើការចាត់វិធានការគ្រប់គ្រងនិងអភិរក្សនោះទេ។

៣. ក្នុងការអនុវត្តអភិក្រមប្រុងប្រយ័ត្នជាមុន រដ្ឋនានាត្រូវ៖

(ក) ធ្វើឱ្យប្រសើរឡើងនូវការធ្វើសេចក្តីសម្រេចចិត្តសម្រាប់ការគ្រប់គ្រង និងការអភិរក្សធនធានជលផលតាមរយៈការទទួលបាន និងការចែករំលែកព័ត៌មានវិទ្យាសាស្ត្រដ៏ប្រសើរបំផុតដែលមាន និងអនុវត្តបច្ចេកទេសដែលត្រូវបានកែលម្អឱ្យប្រសើរឡើង ក្នុងការដោះស្រាយឬឆ្លើយតបនឹងហានិភ័យ និងភាពមិនប្រាកដប្រជា

(ខ) អនុវត្តគោលការណ៍ណែនាំដែលបានចែងនៅក្នុងតារាងឧបសម្ព័ន្ធ២ និងកំណត់បរិមាណផលស្តុកនៃប្រភេទគោលដៅដែលអនុញ្ញាតឱ្យចាប់ ព្រមទាំងចាត់វិធានការ ប្រសិនបើការនេសាទលើសពីបរិមាណផលស្តុកនៃប្រភេទគោលដៅបានកំណត់នោះ ដោយផ្អែកលើមូលដ្ឋានព័ត៌មានវិទ្យាសាស្ត្រដ៏ប្រសើរបំផុតដែលមាន

(គ) ពិចារណាលើភាពមិនជាក់លាក់ដែលទាក់ទងទៅនឹងទំហំនិងផលិតភាពនៃផលស្តុក បរិមាណផលស្តុកគោល ស្ថានភាពផលស្តុកដែលទាក់ទងទៅនឹងបរិមាណផលស្តុកគោល កម្រិត និងរបាយត្រីដែលងាប់ដោយការធ្វើនេសាទ និងផលប៉ះពាល់នៃសកម្មភាពនេសាទលើប្រភេទមិនមែនគោលដៅនិងប្រភេទពាក់ព័ន្ធឬពឹងអាស្រ័យ ក៏ដូចជាស្ថានភាពសាគរសាស្ត្រ សេដ្ឋកិច្ច និងបរិស្ថានដែលបានព្យាករនិងមានស្រាប់

(ឃ) រៀបចំកម្មវិធីស្រាវជ្រាវនិងប្រមូលទិន្នន័យសម្រាប់វាយតម្លៃផលប៉ះពាល់ ការធ្វើនេសាទចំពោះប្រភេទមិនមែនគោលដៅ ប្រភេទពាក់ព័ន្ធឬពឹងអាស្រ័យ និងបរិស្ថានរបស់ប្រភេទទាំងនោះ ព្រមទាំងអនុម័តផែនការចាំបាច់ ដើម្បីធានាដល់ការអភិរក្សប្រភេទទាំងនោះ និងការការពារទីជម្រកដែលមានសារៈសំខាន់ជាពិសេស។

៤. រដ្ឋនានាត្រូវចាត់វិធានការដើម្បីធានាថាការនេសាទទាំងនោះនឹងមិនលើសពីផលស្តុកគោលឡើយ។ ខណៈដែលការនេសាទទាំងអស់នោះលើសពីផលស្តុកគោល រដ្ឋនានាត្រូវចាត់វិធានការភ្លាមៗដោយមិនពន្យារពេលដូចដែលបានកំណត់ក្នុងកថាខណ្ឌ៣ (ខ) ដើម្បីស្តារផលស្តុកនោះឡើងវិញ។

៥. នៅពេលដែលស្ថានភាពផលស្តុកត្រីគោលដៅឬមិនមែនគោលដៅ ឬប្រភេទពាក់ព័ន្ធ ឬប្រភេទពឹងអាស្រ័យដល់កម្រិតព្រួយបារម្ភ រដ្ឋនានាត្រូវយកផលស្តុកនិងប្រភេទត្រីទាំងនោះធ្វើជាប្រធានបទសម្រាប់ពង្រឹងការតាមដានដើម្បីពិនិត្យឡើងវិញនូវស្ថានភាពរបស់វានិងប្រសិទ្ធភាពនៃវិធានការគ្រប់គ្រងនិងអភិរក្ស។ រដ្ឋទាំងនោះត្រូវកែលម្អវិធានការទាំងនោះជាប្រចាំក្នុងពេលដែលមានព័ត៌មានថ្មីៗ។

៦. សម្រាប់របកគំហើញជលផលថ្មី រដ្ឋនានាត្រូវអនុម័តឱ្យបានឆាប់តាមដែលអាចធ្វើទៅបាននូវវិធានការគ្រប់គ្រង និងអភិរក្សដោយប្រុងប្រយ័ត្ន មានដូចជាការកម្រិតបរិមាណផលចាប់និងការកម្រិតសមត្ថភាពនេសាទ។ វិធានការទាំងនោះត្រូវតែស្ថិតនៅជាធរមានរហូតទាល់តែមានទិន្នន័យគ្រប់គ្រាន់ ដើម្បីវាយតម្លៃផលប៉ះពាល់ជលផលប្រកបដោយនិរន្តរភាពយូរអង្វែងនៃផលស្តុកទាំងនោះ នៅពេលដែលវិធានការគ្រប់គ្រងនិងអភិរក្សដោយផ្អែកលើការវាយតម្លៃនោះត្រូវបានអនុវត្ត។ ប្រសិនបើសមស្រប វិធានការបន្ទាប់នឹងធ្វើឱ្យមានការរីកចម្រើនធនធានជលផលបន្តិចម្តងៗ។

៧. ប្រសិនបើបាតុភូតធម្មជាតិមានផលប៉ះពាល់ធ្ងន់ធ្ងរទៅលើស្ថានភាពនៃផលស្តុកត្រីផ្លាស់ទីមធ្យម និងផលស្តុកត្រីផ្លាស់ទីឆ្ងាយ រដ្ឋនានាត្រូវអនុម័តវិធានការគ្រប់គ្រងនិងអភិរក្សជាបន្ទាន់ ដើម្បីធានាថាសកម្មភាពនេសាទទាំងនោះមិនបន្ថែមទម្ងន់ដល់ផលប៉ះពាល់ធ្ងន់ធ្ងរនោះឡើយ។ រដ្ឋនានាត្រូវអនុម័តផងដែរនូវវិធានការគ្រប់គ្រងនិងអភិរក្សជាបន្ទាន់ នៅពេលដែលសកម្មភាពនេសាទបង្ហាញនូវការគំរាមកំហែងយ៉ាងធ្ងន់ធ្ងរដល់និរន្តរភាពនៃផលស្តុកទាំងនោះ។ វិធានការដែលបានដាក់ចេញជាបន្ទាន់នោះត្រូវតែជាវិធានការបណ្តោះអាសន្ននិងត្រូវផ្អែកលើមូលដ្ឋានភស្តុតាងវិទ្យាសាស្ត្រដ៏ប្រសើរបំផុតដែលមាន។

## មាត្រា៧. ភាពស្របគ្នានៃវិធានការគ្រប់គ្រងនិងអភិរក្ស

១. ដោយមិនធ្វើឱ្យប៉ះពាល់ដល់សិទ្ធិបូរណភាពដែនដីនៃរដ្ឋម្ចាស់ឆ្នេរ ក្នុងគោលបំណងធ្វើអាជីវកម្មនិងស្រាវជ្រាវគ្រប់គ្រង និងអភិរក្សធនធានសមុទ្រមានជីវិតនៅក្នុងតំបន់ស្ថិតក្រោមដែនយុត្តាធិការជាតិ ដូចដែលបានផ្តល់ក្នុង

អនុសញ្ញា និងសិទ្ធិរបស់រដ្ឋ សម្រាប់ប្រជាជននៃរដ្ឋទាំងនោះ ធ្វើនេសាទនៅសមុទ្រអន្តរជាតិស្របទៅតាមអនុសញ្ញា៖

(ក) ទាក់ទងនឹងផលស្តុកត្រីផ្លាស់ទីមធ្យម រដ្ឋម្ចាស់ឆ្នេរពាក់ព័ន្ធនិងរដ្ឋដែលមានប្រជានេសាទធ្វើនេសាទផលស្តុកត្រីផ្លាស់ទីមធ្យមទាំងនោះ នៅក្នុងតំបន់ជាប់នឹងដែនសមុទ្រអន្តរជាតិ ត្រូវស្វែងរកការឯកភាពលើវិធានការចាំបាច់ សម្រាប់ការអភិរក្សផលស្តុកទាំងនោះក្នុងតំបន់ជាប់សមុទ្រអន្តរជាតិ តាមរយៈយន្តការផ្ទាល់ ឬសមស្របសម្រាប់កិច្ចសហប្រតិបត្តិការ ដូចមានចែងក្នុងផ្នែកទី៣នៃ កិច្ចព្រមព្រៀងនេះ

(ខ) ទាក់ទងទៅនឹងផលស្តុកត្រីផ្លាស់ទីឆ្ងាយ រដ្ឋម្ចាស់ឆ្នេរពាក់ព័ន្ធនិងរដ្ឋដែលមានប្រជានេសាទធ្វើនេសាទផលស្តុកត្រីនៅក្នុងតំបន់ត្រូវសហការ ដើម្បីធានាការអភិរក្ស និងការលើកកម្ពស់ការប្រើប្រាស់ដ៏ប្រសើរបំផុតនូវផលស្តុកទាំងនោះនៅពាសពេញតំបន់ ទាំងនៅក្នុងនិងខាងក្រៅដែនដែលស្ថិតក្រោមយុត្តាធិការជាតិ តាមរយៈយន្តការផ្ទាល់ឬសមស្របសម្រាប់កិច្ចសហប្រតិបត្តិការដូចមានចែងក្នុងផ្នែកទី៣នៃកិច្ចព្រមព្រៀងនេះ។

២. វិធានការគ្រប់គ្រងនិងអភិរក្សដែលបានបង្កើតឡើងសម្រាប់សមុទ្រអន្តរជាតិ និងវិធានការដែលបានអនុម័តសម្រាប់តំបន់នៅក្រោមដែនយុត្តាធិការជាតិត្រូវតែមានភាពស្របគ្នា ដើម្បីធានាការគ្រប់គ្រងនិងអភិរក្សផលស្តុកត្រីផ្លាស់ទីមធ្យមនិងផលស្តុកត្រីផ្លាស់ទីឆ្ងាយនៅក្នុងស្ថានភាពដើមនិងមិនប្រែប្រួល។ ដើម្បីឈានទៅដល់គោលដៅនេះ រដ្ឋម្ចាស់ឆ្នេរនិងរដ្ឋដែលធ្វើនេសាទនៅក្នុងសមុទ្រអន្តរជាតិ ត្រូវមានកាតព្វកិច្ចធ្វើកិច្ចសហប្រតិបត្តិការ ក្នុងគោលបំណងសម្រេចបាននូវវិធានការស្របគ្នាទាក់ទងនឹងផលស្តុកត្រីទាំងនោះ។ ក្នុងការកំណត់វិធានការគ្រប់គ្រងនិងអភិរក្សស្របគ្នា រដ្ឋនានាត្រូវ៖

(ក) ពិចារណាទៅលើវិធានការគ្រប់គ្រងនិងអភិរក្សដែលអនុម័តនិងអនុវត្តដោយរដ្ឋម្ចាស់ឆ្នេរ ដែលស្ថិតក្រោមដែនយុត្តាធិការជាតិ អនុលោមតាមមាត្រា៦១នៃអនុសញ្ញានេះ ដោយផ្អែកលើផលស្តុកដូចគ្នា និងធានាថាវិធានការទាំងអស់ត្រូវបានបង្កើតឡើងដោយយោងតាមផលស្តុក នៅក្នុងសមុទ្រអន្តរជាតិនឹងមិនធ្វើឱ្យប៉ះពាល់ដល់ប្រសិទ្ធភាពនៃវិធានការទាំងនោះ

(ខ) ពិចារណាទៅលើវិធានការដែលបានព្រមព្រៀងគ្នាបង្កើតឡើង និងអនុវត្តកន្លងមកសម្រាប់សមុទ្រអន្តរជាតិដោយរដ្ឋម្ចាស់ឆ្នេរនិងរដ្ឋធ្វើនេសាទនៅសមុទ្រអន្តរជាតិពាក់ព័ន្ធ អនុលោមតាមអនុសញ្ញាដែលមានផលស្តុកដូចគ្នា

(គ) ពិចារណាទៅលើវិធានការដែលបានព្រមព្រៀងគ្នាបង្កើតឡើង និងអនុវត្តកន្លងមកដោយអង្គការគ្រប់គ្រងជលផលថ្នាក់តំបន់ឬថ្នាក់អនុតំបន់ ឬក្រុមការងារដែលបានរៀបចំឡើងអនុលោមតាមអនុសញ្ញាដែលមានផលស្តុកដូចគ្នា

(ឃ) ពិចារណាទៅលើលក្ខណៈជីវសាស្រ្តផលស្តុកដូចគ្នានិងខុសគ្នា និងទំនាក់ទំនងរវាងរបាយផលស្តុកធនធានជលផល និងលក្ខណៈពិសេសនៃភូមិសាស្រ្តតំបន់ពាក់ព័ន្ធ ដោយគិតទាំងវិសាលភាពផលស្តុកដែលកើតឡើងនិងត្រូវបាននេសាទនៅក្នុងតំបន់ស្ថិតក្រោមដែនយុត្តាធិការជាតិ

(ង) ពិចារណាទៅលើការពឹងផ្អែកលើផលស្តុកពាក់ព័ន្ធរបស់រដ្ឋម្ចាស់ឆ្នេរ និងរដ្ឋដែលធ្វើនេសាទនៅសមុទ្រអន្តរជាតិ

(ច) ធានាថាវិធានការទាំងនោះមិនបង្កផលប៉ះពាល់ដ៏គ្រោះថ្នាក់ ទៅលើធនធានមានជីវិតទាំងអស់នៅក្នុងសមុទ្រ។